# ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៙*៙

លេខ : ៣៦០

ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សាលដីកា

លេខ : ៨៧

ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០០០ បានបើកសវនាការជំនុំជំរះជាសាធារណៈ ដែលមានសមាសភាព ដូចតទៅ ÷

១- ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២- លោក ប៉ែន ស៊ុន ជាចៅក្រម

៣- លោក វៀល មួន ជាចៅក្រម

៤- លោក សោម សិរីវឌ្ឍ ជាចៅក្រមរបាយការណ៍

៥- លោក យស់ សូខឿន ជាចៅក្រម

ក្រឡាបញ្ជី

លោក ស៊ុង ម៉ៅ

តំណាងមហាអយ្យការ

លោក ប៉ែន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៦៤៨ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣២២ ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ រវាង ÷

ម្ចាស់បណ្តឹងសាទុក្ខឈ្មោះ វៀម សាហួត ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ របរកងអាកាសខេមរភូមិន្ទ។ ផ្ទះលេខ ២៦០ ផ្លូវលេខ ១៥០ ក្រុម ២៦ សង្កាត់ទឹកល្អក់ ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ ហៀក អ៊ាង "ស" ម្តាយឈ្មោះ ហុង មុំ "ស" ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ទ្រិញ ណារិន ភេទ ស្រី អាយុ ៤២ ឆ្នាំ ជាតិខ្មែរ របរនៅផ្ទះ ទីលំនៅផ្ទះលេខ ២៨៤ ផ្លូវ ១៥០ ក្រុម ២៦ សង្កាត់ទឹកល្អក់ ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ ទ្រិញ ហុង "រ" ម្តាយឈ្មោះ នៅ ទ្រី "រ" ប្តីឈ្មោះ ហួត សុភា ។

<u>**កម្មវត្ថុបណ្តឹង**</u> : *ទាមទារសំណងជាប្រាក់ ១0000US$ បណ្តាលមកពីការបុកគ្រឹះបណ្តាលអោយប្រេះស្រាំផ្ទះ.*

បានឃើញបណ្តឹងសាទុក្ខលេខ ៣៦៤ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះ រៀម សាហួត មិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ ៦៤៨ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៦៣០ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់ឈ្មោះ ទ្រិញ ណារិន ប្តឹងហាមឃាត់មិនអោយសាងសង់ផ្ទះបន្ថែម និងទារសំណងជាប្រាក់ ១0000**US$** ពីឈ្មោះ រៀម សាហួត ដោយហេតុថា រៀម សាហួត បានសាងសង់ផ្ទះបុកគ្រឹះធ្វើអោយប្រេះស្រាំផ្ទះរបស់ខ្លួន ។

តាមពាក្យបណ្តឹងសុំកិច្ចការប្រញាប់ ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ១៩៩៨ របស់ឈ្មោះ រៀម សាហួត ប្តឹងជំទាស់នឹងដីកាចារលើពាក្យលេខ ៤៨ "ក" ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដោយហេតុថាខ្លួនបានបុកគ្រឹះធ្វើផ្ទះពីរល្វែងនៅថ្ងៃទី ១០ ខែតុលា ឆ្នាំ១៩៩៨ ជាប់ផ្ទះ ទ្រិញ ណារិន ដែលមានការប្រេះស្រាំស្រាប់ ខ្លួនសុំអោយតុលាការចេញដីកាសំរេចកិច្ចការប្រញាប់អោយខ្លួនសង់ផ្ទះបន្តទៀត ។

បានឃើញសាលក្រមលេខ ២០ "ក" ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ ÷

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ មានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២- ទទួលលិខិតពឹងមេធាវីរបស់ដើមចោទ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ១៩៩៨ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣- ទទួលបណ្តឹងតបរបស់ចុងចម្លើយ រៀម សាហួត ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ១៩៩៩ មានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

៤- បង្គាប់អោយចុងចម្លើយឈ្មោះ រៀម សាហួត សងការខូចខាតបណ្តាលមកពីការបុកគ្រឹះផ្ទះចំនួន ៤០០ដុល្លាអាមេរិក និងបង្គាប់អោយចុងចម្លើយរុះរើវេរ៉ង់ដាជាន់ទី១ នៃផ្ទះលេខ ២០៧ ផ្លូវលេខ ១៨០ ក្រុម២៦ សង្កាត់ទឹកល្អក់ ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ដែលមានទទឹង ០.៨ម ចំហៀងខាងលិចដែលជាកម្មវត្ថុទំនាស់តាមលិខិតរបស់មន្ទីររៀបចំក្រុង និងសំណង់លេខ ១៧៥ រកសណ.សជ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៩ និងអោយសងជំងឺចិត្តទៅដើមចោទចំនួន ៨០០ដុល្លាអាមេរិក តាមមាត្រា ១២១ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

សំណូមពរលើសពីនេះបដិសេធចោទ

៥- រឹបអូសប្រាក់ប្រដាប់ក្តីពីឈ្មោះ រៀម សាហួត ចំនួន ៧០០០៛ គឺពន្ធចុះបញ្ជី និងពន្ធហ្វឹងចំនួន១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៣០០០៛ និងរង្វាន់សាក្សី ២០០០៛ បូករួម ៧០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០៛ ដែលដើមចោទឈ្មោះ ទ្រិញ ណារិន បានបង់រួចហើយ ។

៦- កាលបើហួសឧទ្ធរណ៍បង្គាប់អោយឈ្មោះ រៀម សាហួត សងប្រាក់ ៧០០០៛ អោយដើមចោទវិញ និងអោយបង់ពន្ធសមាមាត្រមួយភាគរយលើតំលៃនៃការខូចខាត តំលៃនៃសំណងរវ៉េងដានិងជំងឺចិត្តប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន ៨០% ព្រមទាំងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៧- សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូភាគីសំរេចមកបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញសេចក្តីសុំប្តឹងតវ៉ាលេខ១២"ក" ចុះថ្ងៃទី ២៩ ខែមិនា ឆ្នាំ១៩៩៩ ដែលមានឈ្មោះ ទ្រិញ ណារិន បានប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ ២០"ក" ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចនៃសាលក្រមទាំងមូល ។

បានឃើញសេចក្តីសុំប្តឹងតវ៉ាលេខ ១០ "ក" ចុះថ្ងៃទី ១៥ ខែមិនា ឆ្នាំ១៩៩៩ ដែលមានឈ្មោះ រៀម សាហួត ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ២០"ក" ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦៤៨ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ មានខ្លឹមសារដូចតទៅ ÷

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៥ ខែមិនា ឆ្នាំ១៩៩៩ របស់ឈ្មោះ រៀម សាហួត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៩ ខែមិនា ឆ្នាំ១៩៩៩ របស់នាង ទ្រិញ ណារិន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៣- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ២០"ក" ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដោយកែប្រែត្រង់ចំណុចស្តីពីសំណងប្រាក់ជំងឺចិត្ត ក្រៅពីនេះដកល់ទុកទៅដដែល ។

៤- បង្គាប់អោយឈ្មោះ រៀម សាហួត សងប្រាក់ជំងឺចិត្តចំនួន ២៥០០ដុល្លាអាមេរិក អោយទៅនាង ទ្រិញ ណារិន នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៥- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង ២.៥០០៛ រង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥០០០៛ និងលើអាជ្ញាធរតុលាការ ៥.០០០៛សរុប ១៣.០០០៛ ។

សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៦៤ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះ រឿម សាហួត ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា សាលាឧទ្ធរណ៍បានសំរេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ចុះ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ រឿម សាហួត ពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : សំណើរបស់ខ្ញុំតុលាការថ្នាក់ក្រោមមិនដែលបានពិចារណាទេ ការសង់ផ្ទះខ្ញុំមានច្បាប់អនុញ្ញាតិត្រឹមត្រូវមុនបុកគ្រឹះខ្ញុំបានស្នើពីដើមចោទនិងប្តីអ្នកទាំងពីរបានយល់ព្រម ។ ផ្ទះគាត់ប្រេះស្រាប់ទេ ព្រោះសរសរឈើបុកស៊ីម៉ង់ត៍ពីក្រៅ ពេលខ្ញុំសង់ផ្ទះជិតរួច ទ្រិញ ណារិន ចាប់ប្តឹងខ្ញុំតែម្តងថាការបុកគ្រឹះបណ្តាលអោយខូចផ្ទះគាត់ ។ ដើមចោទបានយកគំនុំផ្ទាល់ខ្លួនមកធ្វើបាបខ្ញុំសូមរកយុត្តិធម៌ផង ចំពោះរបងដាខ្ញុំសុខចិត្តបង់លុយអោយ ទ្រិញ ណារិន វិញ តែកុំវាយចោលព្រោះខូចផ្ទះ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ទ្រិញ ណារិន ពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : ខ្ញុំសូមអោយ រឿម សាហួត រើរបងដាចេញពីដីខ្ញុំនិងសុំសងការខូចខាតបណ្តាលមកពីការបុកគ្រឹះ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ ៣៦៤ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ១៩៩៩ របស់លោក រឿម សាហួត ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចជំនុំជំរះរឿងនេះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា : អង្គភាពជំនាញបានវាយតំលៃថា ការប្រេះស្រាំផ្ទះរបស់អ្នកស្រី ទ្រិញ ណារិន គឺពិតជាបង្កឡើងដោយការសាងសង់របស់លោក រឿម សាហួត ប្រាកដមែន ដូច្នេះ រឿម សាហួត មានកាតព្វកិច្ចជួសជុលការខូចខាតនេះតាមមាត្រា ១២១ នៃច្បាប់ ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

- យល់ឃើញថា: ការសំរេចអំពីសំណងលើការជួសជុលការខូចខាត និងអំពីជំងឺចិត្តមានលក្ខណៈសមរម្យហើយ ។

- យល់ឃើញថា : ការដែលចុងចម្លើយសំណូមពររក្សាវេរង់ជា ហើយសុខចិត្តបង់ប្រាក់ពិន័យនោះ តុលាការពុំមានសមត្ថកិច្ចពិចារណាឡើយ ។

- យល់ឃើញថា : សាលដីការដ្ឋប្បវេណីលេខ ៦៤៨ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ សំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី

១- ទទួលបណ្តឹងសាទុក្ខលេខ ៣៦៤ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ១៩៩៩ របស់លោក វៀម សាហួត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តំកល់សាលដីការដ្ឋប្បវេណីលេខ ៦៤៨ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រី ទ្រិញ ណារិន បានបង់ជូសទៅតុលាការកំពូល ចំនួន ១៩.០០០រៀល គឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

- បង្គាប់អោយលោក វៀម សាហួត បង់ពន្ធសមាមាត្រ ១% លើសំណង និងជំងឺចិត្ត ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០០០ ។